# ប្រលោមលោក សំណោកអនុស្សាវរីយ៍

ផ្ដើមសរសេរនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៣ និងបញ្ចប់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៤។ ក្នុងខែ កញ្ញា ដល់តុលា២០១៩ សាច់រឿងនេះត្រូវបានអ្នកនិពន្ធយកមករៀបចំកែសម្រួលចុងក្រោយម្ដងទៀតដើម្បីបោះពុម្ព។


និពន្ធដោយ : អ្នកនិពន្ធ រតនា

សម្រួលអក្ខរាវិរុទ្ធ : ហ៊ួន ស៊ីឡូន

រចនាក្របនិងទំព័រ : កែវ លាងងួន

គំនូរ : ពណ៌ខ្មៅ

បោះពុម្ពផ្សាយដោយអ្នកនិពន្ធ

បោះពុម្ពលើកទី១ ខែវិច្ឆិកា ឆ្នាំ ២០១៩ ចំនួន ៥០០០ ច្បាប់

កម្រាស់ ២២៥ទំព័រ ខ្នាត ១១.៥ គុណ ១៧.៥ សង់ទីម៉ែត្រ

លេខសម្គាល់សៀវភៅ ISBN-00: 000-0000-0000-0-0



© រក្សាសិទ្ធិគ្រប់បែបយ៉ាង គ.ស. 0000

ចុះបញ្ជីលេខ ® 000 និងអនុញ្ញាតឱ្យបោះពុម្ពផ្សាយលេខ 00 ដោយនាយកដ្ឋានសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

គ្មានផ្នែកណាមួយនៃសៀវភៅត្រូវថតចម្លង ឬផ្សព្វផ្សាយខ្លឹមសារតាមប្រព័ន្ធអេឡិចត្រូនិចដើម្បីរកប្រាក់កម្រៃដោយមិនសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិឡើយ៕

# ទំនាក់ទំនងនិពន្ធ

អ្នកអាចគិតទៅដល់អតីតកាលបាន តែមិនអាចត្រឡប់ទៅរកអតីតកាលវិញបានឡើយ! ដំណើរជីវិតប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ តែងឆ្លងកាត់រឿងរ៉ាវជាច្រើនរាប់មិនអស់ រឿងដែលកើតរួចហើយវានឹងក្លាយជាស្រមោល។ អ្នកអាចមើលឃើញស្រមោលមួយនោះ តែអ្នកមិនអាចឱបក្រសោបវាបានឡើយ។ រឿងដែលកន្លងហួសហើយ នៅសល់តែអនុស្សាវរីយ៍! កំហុសអតីតកាល នឹងក្លាយជាសំណោកអនុស្សាវរីយ៍! អត់មានអ្នកណាចង់សាងកំហុសនោះទេ! តែភាពក្មេងខ្ចីនៃបទពិសោធន៍ ការគិតពិចារណាមិនបានច្បាស់លាស់ ភាពទន់ខ្សោយនឹងនាំឱ្យមនុស្សសាងកំហុសដោយចេតនា និងអចេតនា។

ពេលមួយដែលអ្នកចេះទទួលខុសត្រូវខ្ពស់ អ្នកស្រាប់តែមើលឃើញកំហុសដែលធ្លាប់សាង ព្រោះតែវិប្បដិសារីធ្វើឱ្យអ្នកមិនអាចដើរចេញពីស្រមោលមួយនោះបាន។ អត់មានអ្នកណាចង់សាងកំហុសទេ! ដូច្នេះមិនអាចព្រោះតែអាងលើភាពក្មេងខ្ចី គ្មានបទពិសោធន៍គ្រប់គ្រាន់ក៏ត្រូវតែបណ្តោយឱ្យខ្លួនឯងសាងកំហុសបានដោយងាយៗនោះដែរ។ បើចង់

រស់នៅជាមួយសេចក្ដីសុខឱ្យបានច្រើន ត្រូវចេះរកវិធីដើរចេញពីការសាងកំហុស។ ជីវិតដែលគ្មានវិប្បដិសារី បើទោះជាមានស្នាមញញឹមធម្មតាក៏ជាស្នាមញញឹមបរិសុទ្ធដែរ។ ផ្ទុយទៅវិញ ជីវិតដែលទូលវិប្បដិសារី បើទោះជាអាចញញឹមបានក៏គង់នៅលាក់ទឹកភ្នែកក្នុងបាតបេះដូង។

សំណោកអនុស្សាវរីយ៍! សៀវភៅតូចពណ៌ត្របែកព្រៃនឹងនាំអារម្មណ៍អ្នកអានទៅរកមនោសញ្ចេតនាលន្លង់លន្លោចនៃស្នេហាមួយដែលកើតឡើងកាលពីឆ្នាំ២០០៣។ នាងខ្ញុំបានប្រើអារម្មណ៍ស្រមើស្រមៃរបស់ខ្លួនសរសេររៀបរាប់ជាហូហែរពីដំណើរស្នេហារបស់កំលោះក្រមុំមួយគូ ដោយដាក់បញ្ចូលនូវភាពបរាជ័យ និងភាពជោគជ័យ មានទាំងវិប្បដិសារី ភាពទន់ខ្សោយ និងភាពរឹងមាំរបស់តួអង្គតាំងពីចាប់ផ្ដើមរហូតដល់បញ្ចប់រឿង។អ្នកអានមិនចាំបាច់ចាប់អារម្មណ៍ទេថាស្នេហារបស់គេទាំងពីរនឹងទៅជាយ៉ាងណា? គ្រាន់តែចាប់អារម្មណ៍ថាគ្រប់រសជាតិទាំងឡាយដែលតួអង្គនីមួយៗបានជួប អាចផ្ដល់បទពិសោធន៍ឱ្យអ្នកបានប៉ុណ្ណា? ប្រសិនបើអ្នកស្ថិតនៅក្នុងកាលៈទេសៈរបស់តួអង្គក្នុងរឿង តើអ្នកនឹងដោះស្រាយ

បញ្ហាទាំងនោះដោយវិធីណា? ក្រោយអានសៀវភៅតូចមួយនេះចប់ តើអ្នកនឹងមានការតាំងចិត្តអ្វីខ្លះ? ចង់ផ្លាស់ប្តូរអ្វីខ្លះដើម្បីចៀសផុតពីការរស់នៅក្នុងសំណោកអនុស្សាវរីយ៍មួយនោះ? សំណោកអនុស្សាវរីយ៍! បេះដូងតូចមួយនេះជាស្នាដៃនិពន្ធទីមួយរបស់នាងខ្ញុំ សរសេរឡើងដោយគោលបំណងដាស់តឿនដល់អ្នកអាន ឱ្យមានការគិតពិចារណាច្បាស់លាស់មុនធ្វើការសម្រេចចិត្តផ្សេងៗ។

**ជីវិត! ឱ្យតែអាចរស់នៅ គឺអាចដើរទៅមុខបានរហូត តែអាចដើរទៅជាមួយវិប្បដិសារី ឬសុភមង្គលបរិសុទ្ធវាអាស្រ័យទៅលើភាពម៉ត់ចត់របស់អ្នកហើយ!**

**កុំយកភាពក្មេងខ្ចីធ្វើជាលេស! ព្រោះថានៅពេលដែលអ្នកចេះគិត អ្នកអាចនឹងពិបាកដើរចេញពីសំណោកអនុស្សាវរីយ៍របស់ខ្លួនឯង។**

ដោយក្តីស្រលាញ់

អ្នកនិពន្ធរតនា(ផ្កាយតូច)

# អក្ខកក្លខឆ្លើយ

៣-៥-២០០៣

# ជូនចំពោះអ្នក

ត្រេកអរបំផុតនៅពេលដែលអ្នកព្រមទទួលយកសំបុត្ររបស់ខ្ញុំ អរគុណណាស់ដែលអ្នកមិនធ្វើឱ្យខ្ញុំខកបំណង។ ទោះបីអ្នកមិនយល់ពីហេតុផលដែលខ្ញុំសរសេរសំបុត្រនេះក៏ដោយ។ បើពេលនេះអ្នកកំពុងអានសំបុត្រខ្ញុំនឹងមិនធ្វើឱ្យអ្នកនៅតែឆ្ងល់រហូតទេ ខ្ញុំនឹងប្រាប់អ្នកនៅពេលឥឡូវនេះ។

នាមជានារីខ្មែរម្នាក់ត្រូវគោរពតាមប្រពៃណី។ ប្រពៃណីខ្មែរតឹងតែងណាស់ កូនស្រីត្រូវប្រកាន់ភាពអៀនខ្មាស ត្រូវចេះស្រលាញ់និងរក្សាកិត្តិយស ប៉ុន្តែពេលនេះនារីខ្មែរម្នាក់នេះកំពុងតែធ្វើខុសនឹងក្រឹត្យក្រមប្រពៃណី ទាំងដឹងខ្លួនហើយក៏មិនព្រមកែវិញដែរ តើព្រោះតែអ្វីទៅ? គឺព្រោះតែមនុស្សម្នាក់! ហើយម្នាក់នោះគឺជាអ្នកដ៏ពិតប្រាកដ។ ភាពផ្តាំផ្គងរបស់ខ្ញុំពេលនេះ គឺព្រោះតែខ្ញុំបានបាក់ចិត្តលើអ្នក ខ្ញុំស្រលាញ់អ្នក! វិសេស!

ស្រលាញ់តាំងពីពេលណាក៏មិនដឹង ដឹងតែម្យ៉ាងថា ក្នុងបេះដូងខ្ញុំមានតែអ្នក គ្រប់ដង្ហើមចេញចូលរបស់ខ្ញុំនឹក ដល់តែអ្នក តើអ្នកមានដឹងទេ? អ្នកមានយល់ចិត្តខ្ញុំខ្លះទេ? អ្នកជាបុរសទី១ក្នុងបេះដូងរបស់ខ្ញុំ ជាស្នេហ៍ដំបូងហើយក៏ ជាស្នេហ៍ពិតរបស់ខ្ញុំដែរ។ ចិត្តខ្ញុំពេលនេះលង់ជ្រៅក្នុងអន្លង់ នោះហើយ អារម្មណ៍នេះមិនអាចដើរថយក្រោយវិញបានទេ ខ្ញុំពិតជាមិនអាចកាត់ចិត្តពីអ្នកបានទេ។

គ្រប់កាយវិការរបស់អ្នកធ្វើឱ្យខ្ញុំកាន់តែលង់ជ្រៅទៅ។ ពីមុន ខ្ញុំមិនធ្លាប់ដឹងសោះថាស្នេហាជាអ្វី តែពេលនេះខ្ញុំបាន ស្គាល់ហើយ។ ប៉ុន្តែស្នេហ៍នេះមិនធ្វើឱ្យខ្ញុំមានក្តីសុខក្នុងចិត្ត ឡើយ ផ្ទុយទៅវិញវាធ្វើឱ្យខ្ញុំឈឺចាប់ណាស់ព្រោះតែអារម្មណ៍ ដែលមិនអាចស្មានបេះដូងអ្នកបាន ខ្ញុំស្រពេចស្រពិល ណាស់! ខ្ញុំខ្វល់ណាស់! បារម្ភណាស់! តើចិត្តអ្នកមានខ្ញុំខ្លះ ទេ? ពេលខ្លះខ្ញុំពិតជាលួចសង្ឃឹម តែពេលខ្លះក្តីសង្ឃឹម ធ្លាក់ដល់សូន្យ។ ទទួលអារម្មណ៍ថាចិត្តអ្នកគ្មានខ្ញុំទេ តែបើ ជាការពិតមែននោះ! បើអ្នកមិនមានខ្ញុំក្នុងចិត្តសោះទេនោះ! បើពេលនេះអ្នកបានដឹងអារម្មណ៍ស្នេហ៍តែម្ខាងរបស់ខ្ញុំ ហើយ...

តើអ្នកនឹងវាយតម្លៃខ្ញុំនេះយ៉ាងណាទៅ? មុខក្រាស់មែនទេ? ចិត្តងាយ? ល្ងង់ណាស់មែនទេ?

ក្នុងចិត្តមនុស្សដែលគ្មានអារម្មណ៍ដូចរូបខ្ញុំ ប្រហែលកំពុងគិតថាខ្ញុំនេះថោកទាបណាស់ហើយ ជាមនុស្សស្រីគ្មានភាពខ្មាសអៀនហ៊ានសរសេរសំបុត្រសុំក្ដីស្រលាញ់ពីមនុស្សប្រុសបែបនេះ?

ខ្ញុំក៏ដឹងដែរ វាគួរតែបែបនេះមែនហើយ! មនុស្សស្រី បើធ្វើខុសប្រពៃណី គឺតែងរងពាក្យនិន្ទាជាធម្មតា ខ្ញុំព្រមទទួលទទួលដោយស្មោះ ព្រោះខ្ញុំខុសមែន ប៉ុន្តែតើខ្ញុំគួរធ្វើយ៉ាងណាទៅ? ខ្ញុំពិតជាមិនអាចផ្លាស់ប្ដូររឿងទាំងនេះបានទេ! បេះដូងខ្ញុំបានប្រគល់ឱ្យអ្នកទៅហើយ ពេលនេះគ្រាន់តែចង់សូមដួងចិត្តអ្នកបន្តិចតើបានទេ?

ពិចារណាបេះដូងខ្ញុំផង នេះជាបំណងប្រាថ្នាតែមួយគត់របស់ខ្ញុំ ជាតិនេះ!

**ពីខ្ញុំណារ័ត្ន**

**រង់ចាំចម្លើយពីអ្នក**

៦-៥-២០០៣

# លិខិតឆ្លើយតប

ណារ័ត្នជាទីរាប់អាន! នៅពេលដែលខ្ញុំបានទទួលសំបុត្រពីដៃរបស់អ្នក អារម្មណ៍របស់ខ្ញុំពិតជាមានការងឿងឆ្ងល់ខ្លាំងណាស់ ខ្ញុំមិនយល់ទេថាហេតុអ្វីអ្នកត្រូវធ្វើដូច្នេះ? ក្រោយពីអានសំបុត្ររបស់អ្នកហើយទើបខ្ញុំបានយល់ពីការពិតមួយនោះ។

សេចក្ដីសំបុត្ររបស់អ្នកធ្វើឱ្យខ្ញុំមានការភ្ញាក់ផ្អើលជាខ្លាំង ខ្ញុំមិនដែលនឹកគិតសោះ ថានឹងមានរឿងដូច្នេះកើតឡើងរវាងយើងទាំងពីរ។

ណារ័ត្ន! ទឹកចិត្តរបស់ខ្ញុំចំពោះទំនាក់ទំនងរវាងយើងទាំងពីរ គឺត្រឹមតែជាមិត្តប៉ុណ្ណោះ! ខ្ញុំសុំទោស!

ខ្ញុំមានអារម្មណ៍ថាខ្លួនខ្ញុំកំពុងធ្វើខុសយ៉ាងធ្ងន់ធ្ងរទៅលើអ្នក ខ្ញុំដឹងថាបើទោះខ្ញុំខំនិយាយបែបណាក៏ដោយចុះគ្រប់ពាក្យរបស់ខ្ញុំពេលនេះ សុទ្ធតែបំផ្លាញទឹកចិត្តអ្នក ធ្វើឱ្យអ្នកខកបំណង ធ្វើឱ្យអ្នកឈឺ។ ខ្ញុំពិតជាសោកស្ដាយណាស់ខ្ញុំយល់! ពាក្យសុំទោសមិនអាចដោះស្រាយបញ្ហានេះបាន

ទេ តែខ្ញុំក៏មិនដឹង ថាគួរប្រើពាក្យអ្វីឱ្យសមក្នុងកាលៈទេសៈនេះដែរ។

ណារ័ត្ន! តើខ្ញុំអាចធ្វើអ្វីបានខ្លះដើម្បីជួយអ្នកឱ្យផុតពីការឈឺចាប់នេះទេ? ខ្ញុំពិតជាចង់ជួយអ្នក តើមានវិធីទេ? ខ្ញុំចង់ឱ្យមិត្តភាពរវាងយើងទាំងពីរនៅដូចដើម តើអាចទេ?

ខ្ញុំមិនសង្ឃឹមទេ! ព្រោះពេលនេះខ្ញុំក្លាយជាមនុស្សអាក្រក់ម្នាក់ដែលធ្វើឱ្យអ្នកខូចចិត្តទៅហើយ។ ខ្ញុំមិនបានដឹងខ្លួនសោះថាកាយវិការឬ ទង្វើរមួយណារបស់ខ្ញុំធ្វើឱ្យអ្នកភាន់ច្រឡំ ជ្រុលបាក់ចិត្តមកលើខ្ញុំបែបនេះ ដឹងថាអ្នកឈឺខ្ញុំក៏មានការឈឺចាប់មិនតិចដែរ ខ្ញុំមិនគួរធ្វើឱ្យមិត្តល្អម្នាក់ទទួលការខូចចិត្តយ៉ាងដូច្នេះឡើយ។ ណារ័ត្ន! ខ្ញុំសុំទោស!

ម្យ៉ាងវិញទៀត! ខ្ញុំគ្មានបំណងនិន្ទាឱ្យណារ័ត្នទេ កុំបន្ទោសខ្លួនឯងអី! រ័ត្នមិនល្ងង់ ចិត្តងាយ ឬមុខក្រាស់នោះទេ! ផ្ទុយទៅវិញរ័ត្នជានារីដ៏ក្លាហានម្នាក់ ខ្ញុំពេញចិត្តមនុស្សស្រីមានលក្ខណៈដូចរ័ត្ន ខ្ញុំចង់ស្រលាញ់រ័ត្នណាស់ដែរ! ប៉ុន្តែហេតុអីក៏ចិត្តខ្ញុំមិនអាចស្រលាញ់រ័ត្នបាន? ខ្ញុំមិនយល់ពីខ្លួនឯងទេ មានតែពាក្យសុំទោស!

ជាចុងក្រោយនេះមានតែពាក្យសុំឱ្យរ័ត្ន ពង្រឹងចិត្តឡើង

កុំទន់ជ្រាយ ត្រូវមានស្មារតីនឹងនរ តាំងជំហរឱ្យបានល្អ។ កុំបណ្ដោយឱ្យការឈឺចាប់លុបបាត់អារម្មណ៍ធ្លាប់ស្រស់ស្រាយដែលវ័ត្នធ្លាប់មាន។ កុំភ្លេចថាអ្នកជាមនុស្សធ្លាប់តែរឹងមាំ! រឹងមាំបានទេ? កុំបោះបង់ចោលមិត្តភាពយើងបានទេ?

បែបនេះបានទេ? ខ្ញុំសន្យា! វ័ត្ននឹងជានារីទីមួយ ដែលខ្ញុំពិចារណាបេះដូង ប្រសិនបើខ្ញុំនឹងសម្រេចបើកចិត្តទទួលយកស្នេហា។

**ពីខ្ញុំវិសេស**

អ្នកនិពន្ធវតនា

៨-៥-២០០៣

# ជូនចំពោះអ្នក

អារម្មណ៍មួយ ពេលដែលអ្នកហុចសំបុត្រឆ្លើយតប នោះឱ្យមកខ្ញុំ វារំភើប! ហើយក៏ភ័យ!។ ពេលដែលបានអាន សំបុត្រ តួអក្សរនីមួយៗនៅក្នុងសំបុត្ររបស់អ្នក ប្រានបង្ខំ ភាពអៀនខ្មាសរបស់ខ្ញុំឱ្យចេញមកឡើងទឹកភ្នែកខ្ញុំហូរ! ខ្ញុំ ទទួលអារម្មណ៍ខូចចិត្ត អស់សង្ឃឹមក្រោយទទួលចម្លើយ របស់អ្នក។

អ្វីៗបានហួសអស់ទៅហើយ ចម្លើយរបស់អ្នកបាន បន្សល់ឱ្យខ្ញុំនូវការឈឺចាប់លាយឡំនឹងក្ដីសង្ឃឹម ខ្ញុំទ្រាំញញឹម ទាំងទឹកភ្នែក។ រង់ចាំថ្ងៃស្អែកក្រែងអ្នកផ្លាស់ចិត្ត? ថ្វីបើថ្ងៃ នេះអ្នកផ្ដល់នូវចម្លើយអវិជ្ជមានដល់ខ្ញុំ តែខ្ញុំក៏នៅតែមិនស្អប់ អ្នកដដែល។

វិសេស! អ្នកមិនខុសទេ! កុំសុំទោសខ្ញុំ ខ្ញុំល្ងង់ខ្លួនឯង ទេ! បើអ្នកបដិសេធន៍ខ្ញុំទៅហើយ តើគួរតែមានពាក្យអ្វី ទៀតមកបំបាត់ការឈឺចាប់របស់ខ្ញុំបានទៅ? ហើយក៏គ្មាន វិធីណាដែលអាចធ្វើឱ្យខ្ញុំរួចពីទុក្ខស្នេហានេះដែរ។

អ្នកដឹងទេ? ខ្ញុំកំពុងតែធ្លាក់ទៅក្នុងរណ្ដៅដ៏ជ្រៅមួយ តើខ្ញុំអាចឡើងមកវិញដោយការដើរថយក្រោយបានដែលឬទេ? ប្រសិនបើខ្ញុំអាចធ្វើបាននោះ ខ្ញុំក៏មិនបណ្ដោយឱ្យខ្លួនឯងធ្លាក់ខ្លួនទៅក្នុងរណ្ដៅទុក្ខសោកដូច្នេះដែរ។ វាក៏ដូចជាមិត្តភាពដែលខ្ញុំមានឱ្យអ្នកក្លាយជាស្នេហាទៅហើយ ចុះឱ្យស្នេហាក្លាយជាមិត្តវិញបានដោយវិធីណា? ខ្ញុំប្រាប់អ្នកហើយ! ថាខ្ញុំមិនអាចកាត់ចិត្តបានទេ! ខ្ញុំធ្វើមិនបានទេ! អ្នកដឹងទេថាអារម្មណ៍ដែលទៅមុខមិនរួច ថយក្រោយមិនបានតើវាពិបាកប៉ុនណា?

ពេលដែលបេះដូងមិនសមបំណង តើឈឺចាប់ប៉ុនណាទៅ? ខ្ញុំឈឺចាប់ណាស់! គឺខ្ញុំទេដែលជាអ្នកឈឺចាប់! ព្រោះខ្ញុំជាអ្នកខកបំណង។ ចុះអ្នកវិញហេតុអីក៏ឈឺចាប់ដែរ? ខកបំណងរឿងអី? បញ្ឈឺខ្ញុំ ឬគាប់គួរ?

កុំបារម្ភអី! ខ្ញុំមិនឱ្យអ្នកអាក្រក់ទេ! អ្នកល្អណាស់ ព្រោះតែភាពល្អរបស់អ្នក ទើបខ្ញុំលង់ស្រលាញ់អ្នក ខ្ញុំស្រលាញ់អ្នកដោយខ្លួនឯង។ អ្នកមិនខុសទេ! មិនចាំបាច់ចង់លុបលាងអ្វីទាំងអស់! អាក្រក់ជាខ្ញុំ! ខុសក៏ជាខ្ញុំ! គ្មានទាក់ទងអីនឹងអ្នកនោះទេ កុំចាំបាច់ខូចចិត្តដោយសារខ្ញុំធ្វើអី

ប្រើជីវិតជម្មតារបស់អ្នកវិញចុះវិសេស!

ខ្ញុំដួលខ្លួនឯង ហើយក៏ត្រូវក្រោកឈរវិញដោយខ្លួនឯងដែរ! អ្នកឈប់ខ្វល់នឹងខ្ញុំទៀតទៅ! ខ្ញុំមិនចង់នៅរំខានជីវិតអ្នកតទៅទៀតទេ។ បើបានជាបដិសេធន៍ខ្ញុំទៅហើយ ផ្តល់សង្ឃឹមឱ្យខ្ញុំធ្វើអីទៀត? អ្នកចង់ឱ្យខ្ញុំរង់ចាំការបដិសេធរបស់អ្នកជាលើកទីពីរទៀតមែនទេ? ខ្ញុំពិតជាមានសេចក្តីអៀនខ្មាសនឹងអ្នកខ្លាំងណាស់ តើខ្ញុំមានមុខអីនឹងជួបអ្នកបានទៀតទេ? យើងឆ្ងាយគ្នាចុះ!

**ណារ័ត្ន**



៩-៥-២០០៣

# ជូនចំពោះណារ័ត្ន

ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលឃើញសំបុត្ររបស់អ្នកសៀតជាប់នឹងម៉ូតូរបស់ខ្ញុំ។ ខ្ញុំពិតជាមិនយល់ ហេតុអីក៏អ្នកធ្វើដូច្នេះ? ហេតុអីមិនយកឱ្យខ្ញុំដោយផ្ទាល់ដូចមុន? អ្នកមិនគួរគេចមុខពីខ្ញុំទេ រ័ត្ន!

ខ្ញុំសោកស្តាយណាស់ដែលធ្វើឱ្យអ្នកឈឺចាប់ដូច្នេះ បើដឹងមុនថាតបសំបុត្រអ្នកហើយមានរឿងដូច្នេះកើតឡើងឱ្យខ្ញុំលែងបានជួបមុខអ្នកដូច្នេះ ខ្ញុំក៏មិនធ្វើដែរ។

រ័ត្ន! ខ្ញុំចង់ជួបរ័ត្ន! ចង់ឃើញស្នាមញញឹមរបស់រ័ត្ន មិនចង់ឃើញរ័ត្នទន់ជ្រាយយ៉ាងនេះទេ។ រ័ត្នដឹងទេ? បើរ័ត្ននៅតែគេចមុខពីខ្ញុំ ធ្វើឱ្យខ្ញុំកាន់តែចង់ជួបអ្នកទ្វេឡើង។ ខ្ញុំកាន់តែមានការឈឺចាប់ និងសោកស្តាយ បើរ័ត្ននៅតែធ្វើដូច្នេះតទៅទៀត ខ្ញុំនៅតែគិតថាខ្លួនឯងមានកំហុស។ តើឱ្យខ្ញុំគួរតែធ្វើយ៉ាងណាទៅទើបរ័ត្នរួចផុតពីទុក្ខសោកនេះ? ខ្ញុំចង់ទទួលទុក្ខនេះជំនួសរ័ត្ន ឱ្យខ្ញុំបានលុបលាងទោសកំហុសនេះផងទៅរ័ត្ន។

ខ្ញុំយល់ហើយ! ស្នេហាមិនអាចក្លាយជាមិត្តវិញបាន ខ្ញុំមិនគួរប្រើពាក្យបន្ថែមឱ្យអ្នកកាន់តែឈឺចាប់ទេ! ខ្ញុំចង់ជួយរ័ត្នពិតមែន ចង់លួងលោមចិត្តអ្នកឱ្យធូរស្បើយ។ ខ្ញុំមានវិប្បដិសារីខ្លាំងណាស់ ដែលធ្វើបាបចិត្តរ័ត្នយ៉ាងនេះ! តើខ្ញុំអាចកែប្រែបញ្ហានេះដោយវិធីណាទៅ? ខ្ញុំខុសមែនទេដែលសន្យាផ្ដល់ក្ដីសង្ឃឹមចុងក្រោយឱ្យរ័ត្ន? សម្ដីចុងក្រោយរបស់ខ្ញុំបានបង្ហាញពីភាពអាត្មានិយមណាស់មែនទេ? ខ្ញុំគ្រាន់តែចង់បញ្ជាក់ពីទឹកចិត្តខ្ញុំចំពោះរ័ត្ន ឱ្យរ័ត្នឃើញថាខ្លួនអ្នកមានតម្លៃ មិនមានន័យជាន់ឈ្លីចិត្តរ័ត្នបន្ថែមទៀតនោះទេ! សូមរ័ត្នកុំគិតយ៉ាងដូច្នោះអី!

ដើម្បីឱ្យបញ្ហានេះងាយស្រួលដោះស្រាយ ខ្ញុំគិតថាយើងគួរតែជួបគ្នានិយាយដោយផ្ទាល់តើបានទេ? ល្ងាចនេះខ្ញុំនឹងនៅរង់ចាំអ្នកនៅហាងការ៉េមដែលយើងតែងទៅញ៉ាំជាមួយគ្នា ទោះជារ័ត្នមិនមកក៏ខ្ញុំនៅតែចាំ ខ្ញុំសង្ឃឹមថារ័ត្នមិនទុកឱ្យខ្ញុំនៅរង់ចាំតែម្នាក់ឯងនោះទេ សង្ឃឹមថារ័ត្ននឹងអាណិតចេញមកជួបខ្ញុំតាមសំណូមពរ។

សូមកុំធ្វើឱ្យខ្ញុំកាន់តែមានវិប្បដិសារីទៀតអី ខ្ញុំមិនចង់ឱ្យយើងទាំងពីរត្រូវកាត់ផ្តាច់ទំនាក់ទំនងរវាងគ្នានឹងគ្នាដោយសារតែបញ្ហានេះទេ។

**ពីខ្ញុំវិសេស**

**ល្ងាចនេះចាំអ្នក!**

១៤-០៥-២០០៣

# ជូនចំពោះណារ័ត្ន

ពីម៉ោង៥ល្ងាចដល់ម៉ោងប្រាំបីយប់ ខ្ញុំនៅរង់ចាំអ្នកនៅហាងការ៉េមនោះតែម្នាក់ឯង ព្រោះមិនដែលមានជឿថាអ្នកចិត្តដាច់ដាក់ខ្ញុំដល់ម្លឹង! ហេតុអីមិនមកជួបខ្ញុំ? ក្ដីសង្ឃឹមរបស់ខ្ញុំក៏ប្រែជារលត់សូន្យឈឹង។

រ័ត្ន! តើអ្នកស្អប់ខ្ញុំហើយមែនទេ? ឬនៅខឹងនឹងខ្ញុំ? តើឱ្យខ្ញុំគួរតែធ្វើយ៉ាងណាទៅទើបអ្នកព្រមមកជួបខ្ញុំ? ខ្ញុំពិតជាមានការព្រួយបារម្ភពីទំនាក់ទំនងរវាងយើងទាំងពីរខ្លាំងណាស់! អ្នកមិនស្ដាយពេលវេលាដែលយើងខំរាប់អានគ្នាមកទេឬ? តែចំពោះខ្ញុំវានៅតែមានតម្លៃជាដរាប!

អ្នកចំពោះខ្ញុំគឺសំខាន់! អ្នកធ្លាប់ផ្ដល់កំលាំងចិត្តដល់ខ្ញុំធ្លាប់ជួយខ្ញុំដោះស្រាយរាល់បញ្ហា យើងទាំងពីរនាក់ធ្លាប់រួមយោបល់គ្នាដោះស្រាយបញ្ហារបស់មិត្តឯទៀតដែរ។ ចុះពេលនេះ? យើងពីរនាក់កំពុងមានបញ្ហាជាមួយគ្នាទៅហើយ ហេតុអីមិនរួមគ្នាដោះស្រាយបញ្ហាមួយនោះឱ្យចេញ

ផុតពីយើងទាំងពីរទៅ? តើទុកវាឱ្យនៅនាំតែស្មុគស្មាញចិត្ត យើងធ្វើអី? ខ្ញុំមិនយល់ពីចិត្តអ្នកពេលនេះទេ!

វ័ត្ន! តើពេលនេះអ្នកទៅណាបាត់ហើយ? ពីមុនថ្មើរនេះខ្ញុំនៅទីនេះជាមួយអ្នក តែពេលនេះខ្ញុំនៅម្នាក់ឯង ខ្ញុំខ្វល់ចិត្តណាស់! ខ្ញុំមានអារម្មណ៍ស្តាយក្រោយដែលធ្វើឱ្យអ្នកខូចចិត្ត ខ្ញុំមិនដែលធ្លាប់គិតទាល់តែសោះ ថាយើងទាំងពីរនឹងមានថ្ងៃនេះ។ តែទោះយ៉ាងណា ខ្ញុំមិនអស់សង្ឃឹមទេ ខ្ញុំជឿថានឹងមានថ្ងៃមួយដែលយើងអាចត្រឡប់មកស្និទ្ធស្នាលគ្នាដូចដើមវិញ ទោះជាមួយខែ មួយឆ្នាំ ប្រាំឆ្នាំ ដប់ឆ្នាំក្តី ក៏ខ្ញុំនៅតែចាំ ចាំរហូត! រង់ចាំថ្ងៃមួយនោះ។

ជាចុងក្រោយនេះ ខ្ញុំមិនចង់និយាយអីច្រើនទេ គ្រាន់តែចង់ឱ្យអ្នកដឹងថា ខ្ញុំរង់ចាំទទួលទោសគ្រប់យ៉ាង។ ត្រឡប់មកវិញ! ដាក់ទោសខ្ញុំមកចុះវ័ត្ន! ខ្ញុំមានវិប្បដិសារីណាស់ បើអ្នកនៅតែធ្វើដូច្នេះ។

**ពីខ្ញុំ វិសេស**

**រង់ចាំថ្ងៃមួយ!**

១៣-៧-២០០៣

# ណារ័ត្នជាទីនឹករឭក

វេលាបានកន្លងផុតទៅយ៉ាងយូរ ខ្ញុំនៅតែគិតគូរដល់អ្នកមិនប្រែ។ ចង់ដឹងណាស់ តើអ្នកផ្លាស់ប្តូរអ្វីខ្លះហើយ? ចិត្តឬនិស្ស័យ? សុខទុក្ខរបស់អ្នកយ៉ាងណាដែរ? មានដឹងទេថាខ្ញុំនៅរង់ចាំអ្នក ខ្វល់ពីអ្នកគ្រប់ពេល។

ថ្ងៃមួយដែលនុច្ចកាប្រាប់ខ្ញុំថាអ្នកចេញពីភ្នំពេញហើយនោះ ធ្វើឱ្យខ្ញុំច្របូកច្របល់ខ្វាយខ្វល់ខ្លាំងណាស់ តើអ្នកទៅនៅឯណា? ហេតុអីក៏ហាមមិនឱ្យនុច្ចកាប្រាប់ខ្ញុំ? ខ្ញុំចង់ឱ្យអ្នកយល់ពីអារម្មណ៍របស់ខ្ញុំនៅពេលនេះ។

រ័ត្ន! អ្នកដឹងទេ? នៅពេលដែលអ្នកសារភាពពីចិត្តរបស់អ្នកប្រាប់ខ្ញុំនោះ ខ្ញុំមិនទាន់យល់នៅឡើយទេ ពិតជាមិនដឹងថាអ្វីជាស្នេហានោះទេ តែខ្ញុំខ្វល់ខ្វាយពីអារម្មណ៍អ្នកខ្លាំងណាស់ ចង់បកស្រាយ ចង់ឱ្យគ្រប់យ៉ាងនៅតែល្អ មិននឹកថាប្រែជាល្អក់កករយ៉ាងនេះសោះ។

ក្រោយពេលដែលទទួលសំបុត្រទីពីររបស់អ្នក ធ្វើឱ្យខ្ញុំកាន់តែយល់ចិត្តអ្នកខ្លាំងទៀត យល់ពីការឈឺចាប់របស់អ្នក

ខ្ញុំមិនបានដឹងថាអ្នកចេញទៅពីពេលណានោះទេ អ្នកចេញទៅដោយគ្មានលាមួយម៉ាត់។ ត្រឹមពេលនោះហើយដែលធ្វើឱ្យខ្ញុំគិតដល់អ្នករហូត ចង់ជួបអ្នក! ខ្ញុំនឹកដល់អ្នកគ្រប់ពេលហើយខ្ញុំក៏តែងសួរខ្លួនឯងថា តើខ្ញុំទុកអ្នកជាអ្វី? បើត្រឹមតែជាមិត្តទេ ហេតុអីខ្ញុំត្រូវគិតខ្វល់ខ្វាយពីអ្នកដល់ម្ល៉ឹង? ខ្ញុំដើរសួរមិត្តគ្រប់គ្នា! សួរអ្នកដែលធ្លាប់ស្គាល់ ចម្លើយដែលទទួលបាន "គេថាខ្ញុំល្ងង់ គេថាខ្ញុំស្រលាញ់អ្នកទាំងមិនដឹងខ្លួន" តាមពិតខ្ញុំក៏ស្រលាញ់អ្នក ហើយក៏ស្រលាញ់មកជាយូរដែរ តែហេតុអ្វីខ្ញុំល្ងង់ម្ល៉េះ? មិនស្គាល់ថាស្នេហាជាអ្វី! បណ្តោយឱ្យអ្នកចាកចេញទៅបាន។ តើខ្ញុំពិតជាល្ងង់ណាស់ឬ?

ពេលនេះខ្ញុំខកបំណងគ្រប់យ៉ាងអស់ហើយ! ខ្ញុំស្ទើរតែឆ្កួតទៅហើយពេលអ្នកចេញទៅ ខ្ញុំមានអារម្មណ៍ថាឈឺ។ ពិភពលោកទាំងមូលដូចមានតែខ្ញុំម្នាក់ឯងដែលកំពុងរស់នៅ ខ្ញុំបាត់បង់ស្នាមញញឹម បាត់បង់ក្តីសង្ឃឹម ពេលនេះទើបខ្ញុំកាន់តែយល់ពីទំហំនៃការឈឺចាប់របស់អ្នកនាថ្ងៃនោះ។ រាល់ថ្ងៃខ្ញុំរស់ដូចមនុស្សគ្មានជីវិត តែក៏ត្រេកអរព្រោះខ្ញុំបានលុបលាងនូវកំហុសឆ្គងដែលធ្លាប់បានធ្វើទៅលើអ្នកនៅគ្រានោះ ខ្ញុំបានទទួលក្តីទុក្ខទាំងនេះជំនួសអ្នកហើយ។

រ័ត្ន! ខ្ញុំចង់សួរទៅអ្នកថាព្រមលើកទោសឱ្យខ្ញុំឬនៅ? យល់ពីទំហំនៃសេចក្តីស្រលាញ់របស់ខ្ញុំចំពោះអ្នកដែរឬទេ? តើអ្នកនៅគិតដល់ខ្ញុំទៀតទេ? ឬបំភ្លេចខ្ញុំចេញពីចិត្តបាត់ទៅហើយ? ខ្ញុំចង់ឱ្យអ្នកវិលមកវិញ ចង់ឱ្យភាពជិតស្និទ្ធរបស់យើងមានមកម្តងទៀតបានទេរ័ត្ន?

ខ្ញុំមិនហ៊ានសង្ឃឹមទេ! ក៏មិនហ៊ានប្រាថ្នាច្រើនពេកដែរ សូមឱ្យតែអ្នកឆ្លើយតបនឹងខ្ញុំផងតើបានទេ? តែបើអ្នកមិនឆ្លើយទៀតនោះ ខ្ញុំក៏នៅតែចាំរហូត ខ្ញុំចាំអ្នកជានិច្ច រ័ត្ន!

**វិសេស**

**រង់ចាំអ្នក!**

១៨-៧-២០០៣

# ជូនចំពោះទិសេស

យើងទាំងពីរមិនបានជួបគ្នាមួយរយៈហើយ ខ្ញុំសូមអរគុណនូវការគិតគូររបស់អ្នកចំពោះខ្ញុំ។ បែកពីអ្នកមួយរយៈនេះវាមិនបានធ្វើឱ្យខ្ញុំប្តូរផ្លាស់អីទេ មិនថាចិត្ត ឬនិស្ស័យអ្វីៗទាំងអស់ដែលខ្ញុំធ្លាប់មាននៅដដែលមិនប្រែទេ។

ដ្បិតរឿងកន្លងខ្ញុំធ្វើឱ្យអ្នកខកចិត្តមួយដង ជាពីរដង ក៏ព្រោះតែខ្ញុំមិនហ៊ានប្រឈមមុខនឹងការពិត ការឈឺចាប់ធ្វើឱ្យខ្ញុំបាត់បង់នូវភាពក្លាហាន ទើបខ្ញុំមិនហ៊ានយកសំបុត្រទីពីរឱ្យអ្នកដោយផ្ទាល់ដៃ មិនហ៊ានទៅជួបអ្នកនៅហាងការ៉េម ទាំងខ្ញុំក៏ដឹងដែលថា អ្នកនៅរង់ចាំខ្ញុំ។

ថ្ងៃនោះ ខ្ញុំបានធ្វើដំណើរទៅខេត្តទាំងល្ងាចក្រោយបានទទួលទូរសព្ទពីម៉ាក់មីងរបស់ខ្ញុំ ដែលគាត់បានសំណូមពរឱ្យខ្ញុំទៅនៅកំដរគាត់មួយរយៈ ដោយសារលោកពូរបស់ខ្ញុំគាត់ជាប់ទៅបំពេញកិច្ចការនៅបរទេស។ មុនចេញទៅពីភ្នំពេញ ខ្ញុំបានបើកឡានទៅហាងការ៉េមនោះ ឃើញអ្នកនៅអង្គុយតុដែលយើងតែងអង្គុយជាមួយគ្នារាល់ដង អង្គុយតែ

ម្នាក់ឯង ខ្ញុំពិតជាអាណិតអ្នកណាស់ ខ្ញុំធ្វើបាបអ្នក! តែខ្ញុំពិតជាមិនអាចទៅជួបអ្នកបានឡើយ ដូចបានប្រាប់អ្នករួចហើយ ខ្ញុំគ្មានមុខមាត់នឹងទៅជួបអ្នកបាន ខ្ញុំបានតែត្រឹមលួចមើលអ្នកពីក្នុងឡានតែប៉ុណ្ណោះ។

សុំទោសផង វិសេស! កុំថាខ្ញុំចិត្តដាច់អី! ខ្ញុំមិនចង់អ៊ីចឹងទេ ហើយខ្ញុំក៏មិនហ៊ានខឹងអ្នកដែរ ដែលសំខាន់នោះគឺមិនដែលស្អប់អ្នកម្តងណាសោះ ព្រោះរូបអ្នកជាមនុស្សសំខាន់បំផុតខ្ញុំ។

ខ្ញុំស្តាយក្រោយណាស់ដែលសរសេរសំបុត្រដ៏ឆ្កួតលីលាមួយនោះឱ្យទៅអ្នក ធ្វើឱ្យខកបំណងទាំងសងខាង ហាក់ដូចជាកាត់ផ្តាច់នូវទំនាក់ទំនងល្អរវាងយើងពីមុន។ ខ្ញុំមានអារម្មណ៍ស្តាយក្រោយមែនណ៎ា វិសេស! ស្តាយនូវអ្វីគ្រប់បែបយ៉ាងដែលជ្រុលហួស តែក៏មិនអាចកែប្រែវិញបានដែរ។

ខ្ញុំក៏ចង់ដោះស្រាយបញ្ហានេះឱ្យជ្រះស្រឡះដែរ ប៉ុន្តែស្តាយណាស់ ដែលយើងមិនអាចរួមឃោលបល់គ្នាបានដូចពីមុនទៀត ខ្ញុំពិតជាមិនអាច! អ្នកកុំខឹងនឹងខ្ញុំតើបានទេ? រឿងទាំងអស់នេះក៏ព្រោះតែកាលៈទេសៈបង្ខំខ្ញុំទេ ខ្ញុំដឹងថា

អ្នកព្យាយាមជួបខ្ញុំទើបខ្ញុំហាមនុច្ចកាមិនឱ្យប្រាប់អ្នកពីអាសយដ្ឋានរបស់ខ្ញុំ។ តែពេលនេះអ្នកក៏បានដឹងថាខ្ញុំនៅខេត្តហើយ គួរតែអស់សង្ស័យទៀតទៅ ឈប់ព្យាយាមជួបខ្ញុំទៀតទៅ!

ខ្ញុំសុំអ្នករឿងមួយតើបានទេវិសេស? ខ្ញុំចង់ឱ្យអ្នកឈប់យករឿងទាំងនេះមកទុកក្នុងចិត្តទៀត ប្រើជីវិតធម្មតារបស់អ្នកវិញចុះ។ អ្នកមិនដែលធ្វើអីឱ្យខុសឆ្គងនឹងខ្ញុំទេ តើអ្នកមានទោសកំហុសឯណាមកសុំឱ្យខ្ញុំលើកលែងឱ្យនោះ? វិសេស! អ្នកចង់ឱ្យខ្ញុំប្រាប់អ្នកម្តងទៀតតើមែនទេ? បាន! ខ្ញុំស្រលាញ់អ្នក! នៅតែស្រលាញ់ ហើយស្រលាញ់ជារៀងរហូតទៅ! ខ្ញុំនឹកដល់អ្នកគ្រប់ដង្ហើមចេញចូលគិតដល់អ្នកគ្រប់នាទី តើឱ្យខ្ញុំភ្លេចអ្នកម្តេចបានទៅ?

តែឱ្យខ្ញុំវិលវិញនោះ ហួសពេលហើយ! អរគុណសម្រាប់ក្តីស្រលាញ់របស់អ្នកដែលមានឱ្យខ្ញុំពេលនេះ សោកស្តាយណាស់ដែលអ្នកទើបតែដឹង និងប្រាប់ខ្ញុំពេលនេះ អ្វីៗក៏ហួសអស់ហើយដែរ ព្រោះខ្ញុំបានសន្យាជាមួយម៉ាក់ធំរបស់ខ្ញុំថានឹងទៅរស់នៅប្រទេសកាណាដាជាមួយគាត់ក្នុងពេលឆាប់ៗនេះហើយ ប៉ាម៉ាក់ខ្ញុំក៏បានអនុញ្ញាតហើយដែរ។

គ្រប់យ៉ាងពួកគាត់បានរៀបចំរួចហើយ ផ្លូវមួយនេះខ្ញុំសម្រេចហើយ ខ្ញុំគ្រាន់តែចាប់ចង់ចាកចេញពីកន្លែងខកបំណងមួយនេះ ទើបអ្វីៗអាចធ្វើបានឆាប់រហ័សបែបនេះ។

ខ្ញុំសោកស្ដាយការស្រលាញ់របស់អ្នកខ្លាំងណាស់ ក្ដីសង្ឃឹមចុងក្រោយដែលខ្ញុំរង់ចាំនោះបានមកដល់ហើយ តែក៏ចាប់មិនបាន ខ្ញុំគ្មានវាសនាបានរក្សាបេះដូងអ្នកទេ ទុកឱ្យនារីផ្សេងដែលល្អជាងខ្ញុំចុះ! ខ្ញុំខកបំណងហើយជាតិនេះ ចាំជួបជាតិក្រោយចុះ!

ចុងក្រោយនេះ សូមអ្នកបំភ្លេចរូបខ្ញុំចោលចុះ! បំភ្លេចរឿងទាំងប៉ុន្មានដែលកន្លងមកនេះ ប្ដូរយកជីវិតដែលពោរពេញទៅដោយភាពស្រស់ស្រាយ និងក្ដីសង្ឃឹម ព្រមទាំងស្នាមញញឹមដ៏សែនស្រស់របស់អ្នកមកវិញល្អជាង។ ចំពោះសម្ពន្ធភាពរវាងយើងទាំងពីរ បើអាចធ្វើបាន យើងនៅតែជាមិត្តដ៏សែនល្អនឹងគ្នាដូចគ្រាមុនណាំវិសេស!

**ពីរ័ត្ន**

**រង់ចាំជាតិក្រោយ!**



*២៣-៧-២០០៣*

# រ័ត្នជាទីស្រលាញ់របស់ពីបេះដូង

ខ្ញុំមានសេចក្តីរំភើបក្រៃលែងដែលរ័ត្នព្រមតបសំបុត្ររបស់ខ្ញុំ។ អរណាស់ដឹងទេ? ទោះយ៉ាងណាក៏បានដឹងដំណឹងពីរ័ត្នខ្លះដែរ សេចក្តីព្យាយាមរបស់ខ្ញុំម្តងនេះមិនខកបំណងឡើយ។ ប៉ុន្តែវាចាសំបុត្ររបស់រ័ត្នធ្វើឱ្យខ្ញុំរន្ធត់ចិត្តណាស់ ខ្ញុំស្ទើរតែមិនអាចទប់លំនឹងខ្លួនឯងបាន។

តើអ្វីដែលរ័ត្នប្រាប់ខ្ញុំនេះជាការពិតទេ? រ័ត្នកុហកខ្ញុំទេមែនទេ? រ័ត្នគ្រាន់តែចង់បញ្ឈឺខ្ញុំឱ្យស្មើការឈឺចាប់របស់រ័ត្នពីមុនពិតទេ? តាមពិតគ្មានរឿងដូច្នេះកើតឡើងនោះទេមែនទេ? រ័ត្នប្រាប់មក! វាពិតជាដូចខ្ញុំនិយាយមែន! ប្រាប់មករ័ត្ន!

ខ្ញុំមិនជឿទេ! ខ្ញុំមិនទទួលស្គាល់រឿងទាំងនេះទេ! ខ្ញុំចង់ចាំរ័ត្ន! រ័ត្ននឹងមកវិញ ហើយយើងទាំងពីរនឹងក្លាយជាគូស្នេហ៍មួយគូដែលមានតែភាពផ្អែមល្ហែម មានមនុស្សទាំងពួងលួចច្រណែន មែនទេ? មែនទេរ័ត្ន? ព្រោះយើងទាំងពីរនាក់ស្រលាញ់គ្នាខ្លាំងណាស់ រវាងយើងទាំងពីរពិត

ជាមិនអាចអត់អ្នកណាម្នាក់បានទេ ខ្ញុំនឹងឆ្ងល់បើវ័ន្នមិន អាណិត វ័ន្នយល់ចិត្តខ្ញុំទេ?

វ័ន្នប្រាប់ខ្ញុំមកតើវ័ន្នមកវិញថ្ងៃណា? ខ្ញុំនឹងចាំទទួលវ័ន្ន ឬក៏វ័ន្នប្រាប់អាសយដ្ឋានរបស់វ័ន្ននៅខេត្តក៏បាន ខ្ញុំនឹងទៅ ទទួលវ័ន្នមកវិញ។ យើងនឹងបាននៅក្បែរគ្នាដូចមុន ហើយខ្ញុំ នឹងផ្គាប់ចិត្តវ័ន្នមិនឱ្យទាស់ ខ្ញុំសន្យាណ៎ាវ័ន្ន! វ័ន្នជឿខ្ញុំទៅ វ័ន្ន មកវិញណ៎ា ត្រឡប់មកវិញ ខ្ញុំនៅរង់ចាំ ចាំតែវ័ន្នម្នាក់គត់។

ខ្ញុំសង្ឃឹមថាវ័ន្ននឹងយល់ដល់ជម្រៅចិត្តខ្ញុំ វិលវិញតាម សំណូមពរ។ បើវ័ន្នមិនអាណិតទេនោះ ខ្ញុំនឹងស៊ូនៅគិតម្នាក់ ឯងរង់ចាំថ្ងៃមួយដែលវ័ន្នមេត្តា។ ខ្ញុំមិនជឿថាវ័ន្នដាច់ចិត្តធ្វើ បាបខ្ញុំម្តងទៀតនោះទេ តែបើសិនវ័ន្នចិត្តដាច់មែន ទោះបី វិសេសម្នាក់នេះក៏ព្រមទទួលហើយនៅតែចាំ នៅតែនឹក នៅ តែស្រលាញ់ភ្លេចមិនបាន។

**ពីវិសេស**

**រង់ចាំ!**

អ្នកនិពន្ធរតនា

៥-៨-២០០៣

# វិសេសជាទីនឹករព្ញក

វិសេសដឹងទេ? រ័ត្នឹកវិសេសណាស់ នឹកអស់ពីបេះដូង! រ័ត្នក៏ចង់ជួបវិសេសណាស់ដែរ តែរ័ត្នមិនអាចទៅជួបអ្នកបានទេ ព្រោះលោកពូនៅមិនទាន់បំពេញកិច្ចការរួចនៅឡើយ ហើយបើសិនដល់ថ្ងៃនោះ ក៏ជាថ្ងៃដែលរ័ត្ននឹងចេញទៅកាណាដាបន្តទៀតដែរ ក៏មិនដឹងថាថ្ងៃណារ័ត្នវិលមកវិញទេ ឬក៏គ្មានថ្ងៃនោះផងក៏មិនដឹង។

វិសេស! ស្តាប់ណ៎ា អ្នកត្រូវទទួលស្គាល់ការពិត។ រ័ត្នមិនដែលមានចិត្តចង់បញ្ឈឺអ្នកទេ រ័ត្នធ្លាប់ឈឺចាប់ រ័ត្នក៏យល់ពីចិត្តរបស់មនុស្សដែលឈឺចាប់ដូចគ្នា ពិសេស គឺយល់ចិត្តអ្នក។ រ័ត្នយល់ចិត្តអ្នកណាស់វិសេស ព្រោះរ័ត្នស្រលាញ់អ្នកស្រលាញ់ណាស់! រ័ត្នមិនដែលលមានចិត្តចង់ធ្វើបាបអ្នកទេ វិសេស! តើរ័ត្នធ្វើម៉េចនឹងដាច់ចិត្តធ្វើបាបមនុស្សជាទីស្រលាញ់របស់រ័ត្នបានទៅ? តែរ័ត្នមានកម្មមិនបាននៅក្បែរមនុស្សជាទីស្រលាញ់ ព្រោះចំនងសន្យាបានចងរឹតខ្លួនរ័ត្នមិនឱ្យទៅជួបអ្នកបាន ព្រោះតែពាក្យសន្យា!

វិសេស! រ័ត្នសុំចិត្តអ្នកបានទេ? សុំទៅចុះ ឈប់ធ្វើចិត្តឱ្យទន់ខ្សោយទៀតទៅ ឈប់ធ្វើខ្លួនបែបនេះទៀតតើបានទេ? ដឹងទេថារ័ត្នបារម្ភ? មែនណ៎ាវិសេស!

បើមាននិស្ស័យយើងនឹងបានជួបគ្នាជាថ្មី តែរ័ត្នចង់ឱ្យបានជួបរហូត មិនមែនជួបដើម្បីបែកគ្នាទៀតនោះទេ។ ដូច្នេះហើយទើបរ័ត្នមិនអាចប្រាប់វិសេសឱ្យដឹងពីអាសយដ្ឋានរបស់រ័ត្ននៅទីនេះ មិនចង់បានការជួបហើយព្រាត់ ធ្វើឱ្យមានការឈឺចាប់កាន់តែទ្វេឡើងទៀតនោះទេ។ ហេតុផលប៉ុណ្ណឹងល្មមវិសេសយល់ដល់ចិត្តរ័ត្នផង។

រ័ត្នសង្ឃឹមថាវិសេសនឹងយល់ដល់ចិត្តរ័ត្ន ចង់ឱ្យវិសេសដឹងថា រ័ត្នម្នាក់នេះនៅតែស្រលាញ់ហើយនឹកគិតដល់វិសេសរហូតមក។ រ័ត្នអាណិតអ្នកណាស់! វិសេសយល់ចិត្តរ័ត្នទេ?

**ពីរ័ត្ន**

**មាននិស្ស័យគង់ជួបគ្នា**

អ្នកនិពន្ធរតនា

១០-៨-២០០៣

# រ័ត្នកំពូលដួងចិត្ត

រ័ត្នខឹងខ្ញុំមែនឬ? ខ្ញុំរំភើបស្ទើរតែហោះទៅហើយ ខ្ញុំក៏នឹក រ័ត្នណាស់ដែរ នឹកលើសដែលរ័ត្ននឹកខ្ញុំទៅទៀត រ័ត្នជាម្ចាស់ ជីវិតខ្ញុំ។ បើពេលណាមួយដែលរ័ត្ននឹងចាកចេញទៅកាន់តែ ឆ្ងាយពីខ្ញុំជាងនេះទៅទៀតនោះ ជីវិតរបស់ខ្ញុំក៏លែងមាន ន័យអ្វីតទៅទៀតដែរ។

រ័ត្ន! ដើម្បីរ័ត្ន វិសេសម្នាក់នេះព្រមទាំងអស់ ព្រមធ្វើអ្វី គ្រប់យ៉ាងដែលរ័ត្នត្រូវការ។ ខ្ញុំព្រមទទួលនូវការពិតគ្រប់ បែបយ៉ាងដែលរ័ត្នបានប្រាប់ វិសេសព្រមទទួលហើយ ជឿ ហើយថារ័ត្ននឹងឃ្លាតកាន់តែឆ្ងាយពីជីវិតរបស់វិសេស ប៉ុន្តែ វិសេសក៏សូមអ្វីម្យ៉ាងពីរ័ត្នវិញបានទេ? វិសេសចង់ជួបមុខរ័ត្ន ចង់ឃើញម្ចាស់ស្នេហ៍ម្ចាស់ជីវិតរបស់វិសេសម្តងទៀត មុន ពេលដែលរ័ត្នឈានជើងឡើងយន្តហោះចេញពីជីវិតកំព្រា បេះដូងមួយនេះ ទៅកាន់ពិភពដែលមានតែភាពល្អស្រស់ ផើតឆាយ ហើយក៏មិនដឹងថ្ងៃណាបានជួបជាថ្មី ជួបស្នេហ៍ របស់វិសេស។ សុំតែប៉ុណ្ណឹង! ឱ្យវិសេសបានទេ? ខ្ញុំនឹងមិន ធ្វើខ្លួនឱ្យទន់ខ្សោយដូចនេះទៀតទេ ខ្ញុំនឹងខំពង្រឹងចិត្តឱ្យ

រឹងមាំ គឺដើម្បីតែរ័ត្នម្នាក់គត់។ យ៉ាងនេះក៏ព្រោះតែវិសេស ស្រលាញ់រ័ត្ន ស្រលាញ់ពេញបេះដូង ហើយក៏ស្រលាញ់ ពេញមួយជីវិតផងដែរ។

វិសេសយល់ចិត្តរ័ត្នណាស់ ក៏ចង់ឱ្យរ័ត្នយល់ចិត្តវិសេស វិញផងដែរ។ ទោះពេលនេះរ័ត្នមិនប្រាប់ពីអាសយដ្ឋាននៅ ខេត្តឱ្យខ្ញុំដឹងក៏មិនថ្វីទេ តែក៏សុំចិត្តរ័ត្នកុំលាក់ពីអាសយដ្ឋាន នៅកាណាដានឹងខ្ញុំអី កុំផ្តាច់ទំនាក់ទំនងជាមួយខ្ញុំអី ប្រសិនបើរ័ត្ននឹងទៅហើយ។ យ៉ាងណាក៏វិសេសសូមឱ្យរ័ត្ន ទាក់ទងមកផង ទោះតាមលិខិតដូចនេះទៀតក៏អស់ចិត្តដែរ ដ្បិតអីវិសេសចង់ភ្ជាប់និស្ស័យនឹងរ័ត្នរហូតទៅ ទោះបីជាតិច តួចក៏នៅតែប្រាថ្នា។

ចុងក្រោយនេះវិសេសគ្មានអ្វីចង់បញ្ជាក់ដល់រ័ត្នទៀតទេ តែសូមឱ្យរ័ត្នដឹងថា អ្វីដែលរ័ត្នត្រូវការ វិសេសនឹងព្យាយាម ធ្វើដើម្បីរ័ត្ន។ លើលោកនេះគ្មាននរណាស្រលាញ់រ័ត្ន ឬនឹករ័ត្ន ឱ្យស្មើវិសេសបានទេ។ រ័ត្នដឹងទេ? ហើយក៏គ្មានអ្នកណា អាចជំនួសរ័ត្នក្នុងបេះដូងរបស់វិសេសបានដែរ!

**ពីវិសេស**

**ស្រលាញ់រ័ត្នណាស់!**

*អ្នកនិពន្ធរតនា*

*១៥-០៨-២០០៥*

# ពិសេសម្ចាស់ស្នេហ៍

ត្រឹមដឹងថាពិសេសនឹក រ័ត្នអររកអ្វីប្រៀបមិនបានឡើយ កាន់តែដឹងថាពិសេសនឹកលើសដែលរ័ត្ននឹកទៀតនោះ ធ្វើឱ្យរ័ត្នកាន់តែរំភើបអស់ពីបេះដូងស្នេហ៍។ រ័ត្នស្ទើរមិនហ៊ានបិទភ្នែកគេងព្រោះខ្លាចភ្លេចពាក្យដ៏មានតម្លៃនេះ។ រ័ត្ននិយាយមែន!

ពិសេស! រ័ត្នអរគុណអ្នកខ្លាំងណាស់ ដែលព្រមធ្វើនូវអ្វីដែលរ័ត្នសុំ។ រ័ត្នគ្រាន់តែចង់ឱ្យពិសេសព្រមទទួលស្គាល់ការពិត ទទួលដឹងថារ័ត្ននឹងឃ្លាតទៅ ទៅកន្លែងមួយដែលឆ្ងាយធ្វើឱ្យយើងឃ្លាតកាយឆ្ងាយពីគ្នា តែចិត្តបេះដូងមិនឆ្ងាយគ្នាទេ ដ្បិតអីរ័ត្នចាកចេញតែកាយ ឯបេះដូងផ្ញើរទុកនឹងពិសេសយូរហើយ។ ចិត្តរ័ត្ននឹកគិតដល់អ្នកគ្រប់ពេល ដូចបានប្រាប់រាល់ដងហើយ។

ពិសេសដឹងទេថារ័ត្នត្រេកអរបំផុតព្រោះតែរឿងមួយទាយបានទេថារឿងអី? ព្រោះតែរ័ត្នបានសម្រេចនូវប្រាថ្នាមួយ ពីមុនរ័ត្នតែងប៉ុនប៉ងឱ្យខ្លួនឯងបានក្លាយជាម្ចាស់ស្នេហ៍របស់ពិសេស ហើយពេលនេះរ័ត្នក៏បានសម្រេចនូវ

បំណងប្រាថ្នានេះ។ វិសេសគឺជាអ្វីៗទាំងអស់របស់រ័ត្ន តើដឹងទេ? ពេលនេះរ័ត្នចង់តបស្នងដល់វិសេសវិញ ព្រោះអ្នកតែងតែឱ្យនូវអ្វីដែលរ័ត្នចង់បាន ហើយថ្ងៃនេះរ័ត្ននឹងឱ្យនូវអ្វីដែលអ្នកត្រូវការវិញ។ រ័ត្នព្រមតាមវិសេសទៅចុះ! ព្រមជួបវិសេសម្តងទៀត ជួបមុនពេលដែលរ័ត្នចេញទៅ ទៅចោលបេះដូងមួយដែលរ័ត្នប្រាថ្នាទាំងរ័ត្នក៏មិនដាច់ចិត្ត។

វិសេស! រ័ត្នសូមសន្យា! បើរ័ត្នច្បាស់ថានឹងចាកចេញទៅនាថ្ងៃណានោះ រ័ត្ននឹងប្រាប់អ្នកភ្លាមដែរ ថាអ្នកជាមនុស្សទីមួយដែលបានទទួលដំណឹងពីរ័ត្នដោយផ្ទាល់ អ្នកជឿចុះវិសេស! ពាក្យមួយដែលវិសេសប្រាប់នោះ រ័ត្នក៏ព្រមជឿហើយដែរ ថាលោកនេះពិតជាគ្មាននរណាស្រលាញ់នឹកគិតដល់ រ័ត្នឱ្យស្មើនឹងវិសេសទេ។ រ័ត្នសូមទទួលពាក្យពិតទាំងនេះទុកក្នុងបេះដូងដោយចាក់សោរជាសម្ងាត់។

សូមវិសេសទទួលដឹងផង ថារ័ត្នមានតែវិសេសម្នាក់គត់ ទំហំស្នេហ៍របស់វិសេសចំពោះរ័ត្នប៉ុនណា រ័ត្នក៏មានចំពោះវិសេសប៉ុណ្ណឹងដូចគ្នា។

**ពីណារ័ត្ន**

**ស្រលាញ់ណាស់!**

២៨-០៨-២០០៣

# រ័ត្នម្ចាស់ដួងចិត្ត

វិសេសនឹកណាស់! នឹកតែរ័ត្នម្នាក់គត់ នឹកគ្រប់វិនាទីទាំងអស់។ ត្រឹមដឹងថារ័ត្នត្រេកអរនឹងសេចក្តីនឹករឭករបស់ខ្ញុំ ខ្ញុំក៏រំភើបណាស់ដែរ។ តែរ័ត្នមិនត្រូវលែងចង់គេងបែបនេះទេ រ័ត្នត្រូវគេងខ្លះផង កុំពិបាកចិត្ត! កុំគិតច្រើនពេក! ហើយក៏កុំខ្លាចថានឹងអាចភ្លេចពាក្យនឹករបស់ខ្ញុំបាន។

វិសេសមិនបណ្តោយឱ្យរ័ត្នភ្លេចពាក្យចេញពីបេះដូងទាំងនេះបានទេ វិសេសនឹងប្រាប់រ័ត្នរហូតថា វិសេសនឹករ័ត្នខ្លាំងៗណាស់។ បើពាក្យនេះមានតម្លៃសម្រាប់អ្នកមែននោះវិសេសត្រេកអរណាស់រ័ត្ន!

តែភាពរំភើបរីករាយទាំងនេះវានឹងរលាយបាត់នៅថ្ងៃមួយដែលរ័ត្នចាកចេញទៅ ទៅចោលបេះដូងមួយដ៏កំព្រារបស់វិសេស។ បើរ័ត្នមិនដាច់ចិត្តទេ ហេតុអ្វីមិនទទួលយកបេះដូងនេះទៅជាមួយផង? ហេតុអីមិនទទួលរក្សាបេះដូងរបស់វិសេសផងទៅ? ដាច់ចិត្តម្ល៉េះរ័ត្ន? ព្រមទទួលយកការនឹកពីខ្ញុំទៅហើយហេតុអីមិនទទួលបេះដូងខ្ញុំ?

បើទោះយើងនៅឆ្ងាយយ៉ាងណា វិសេសគ្រាន់តែសុំបន្តនិស្ស័យស្នេហ៍ជាមួយវត្ថុរហូតដល់ថ្ងៃយើងមានវាសនា។ ចំណែកឯបេះដូងរបស់វត្ថុវិញ វិសេសបានទទួលទុកជាយូរមកហើយ។ វត្ថុមិនត្រឹមតែជាម្ចាស់ស្នេហ៍ ម្ចាស់ចិត្តរបស់វិសេសប៉ុណ្ណឹងទេ លើសពីនេះទៅទៀត វត្ថុជាម្ចាស់បេះដូង ម្ចាស់ជីវិត ជាម្ចាស់លើអ្វីៗដែលវិសេសមាន។

អរគុណដែលវត្ថុព្រមឱ្យនូវអ្វីដែលវិសេសសុំ ថ្ងៃនោះខ្ញុំនឹងរៀបចំខ្លួនឱ្យបានសមរម្យ ព្រោះវាជាថ្ងៃដំបូងដែលយើងជួបគ្នាក្រោយកំណើតស្នេហ៍បានកើតឡើង បើទោះថ្ងៃនោះជាថ្ងៃជូនដំណើរវត្ថុទៅកាន់តែឆ្ងាយ តែវានៅតែមានន័យសម្រាប់ស្នេហ៍យើង។ មួយទៀតវិសេសក៏ព្រមជឿថា បេះដូងវត្ថុមានតែវិសេសម្នាក់ ខ្ញុំយល់ហើយ ពីទំហំស្នេហ៍របស់វត្ថុ។

ក្នុងមួយជីវិតនេះ អ្វីដែលវិសេសចង់បាននោះ គឺអ្វីដែលវត្ថុផ្តល់ឱ្យ ហើយអ្វីដែលវិសេសតែងប្រាថ្នានោះ គឺជារូបវត្ថុដ៏ប្រាកដ។ ជីវិតមានន័យព្រោះវត្ថុត្រូវការ បើវត្ថុនឹងប្រាថ្នាអ្វីពីវិសេសទៀតនោះ ក៏វិសេសនឹងរកមកឱ្យវត្ថុឱ្យទាល់តែបាន មិនឱ្យវត្ថុទាស់ចិត្តឡើយ។

**វិសេស**

**អ្វីៗក៏ដើម្បីវត្ថុ!**

អ្នកនិពន្ធរតនា

១៣-១០-២០០៣

# វិសេសកំពូលស្នេហ៍

មួយរយៈមកនេះទំនាក់ទំនងរវាងយើងទាំងពីរកាន់តែមានភាពជិតស្និទ្ធទ្វេរឡើង ពួកយើងបានយល់ចិត្តគ្នាកាន់តែច្រើន។ វាចាស្នេហ៍ដ៏ផ្អែមល្ហែមដែលយើងសាសងតាមសំបុត្រកាន់តែផ្អែម កាន់តែពីរោះ មានន័យខ្លឹមសារ មួយរយៈកន្លងមកនេះអ្នកធ្វើឱ្យជីវិតខ្ញុំមានន័យខ្លាំងណាស់។

សេចក្ដីសំបុត្ររបស់អ្នក ខ្ញុំអានហើយអានទៀតមិនជិនណាយ សោកស្ដាយពេលវេលាដែលមានកាន់តែតិចទៅស្នេហ៍ទើបយល់ចិត្ត ក៏ប្រែឃ្លាតឆ្ងាយ។

វិសេស! រ័ត្នទឹងឃ្លាតពីអ្នកក្នុងពេលឆាប់ៗនេះហើយមិនយូរទៀតទេវិសេស! លោកពូបានមកពីបរទេសវិញហើយ រ័ត្នមានពេលតែមួយសប្ដាហ៍ទៀតទេសម្រាប់ជីវិតនៅប្រទេសកម្ពុជា រំលងពីនេះទៅជីវិតរបស់រ័ត្ននឹងរសាត់អណ្ដែតទៅដល់ទីកន្លែងមួយដែលជាដែនដីនៃប្រទេសកាណាដា។

រ័ត្នខ្លួនឯងក៏មិនដឹងថាពេលនោះជីវិតរ័ត្ននឹងទៅជាយ៉ាងណាទេ។ វិសេស! រ័ត្នមិនចង់បែកពីអ្នកទៀតទេ ឆ្ងាយ

ត្រឹមប៉ុណ្ណឹង វ័ន្ទនឹកអ្នកស្ទើរផុតដង្ហើម ចុះទម្រាំតែកាន់តែឆ្ងាយជាងនេះទៀតនោះ តើឱ្យវ័ន្ទនឹកអ្នកខ្លាំងយ៉ាងណាទៀតទៅ? វ័ន្ទប្រាកដជានឹកអ្នកស្លាប់មិនខាន។ វ័ន្ទមិនចង់គិតទេ! តែមិនប៉ុន្មានថ្ងៃទៀតទេ វ័ន្ទនឹងត្រូវទៅហើយ! តើមិនឱ្យខ្ញុំគិតម្ដេចនឹងបានទៅ?

ពេលដែលដឹងថានឹងត្រូវឃ្លាតឆាប់ៗ ទើបខ្ញុំដឹងថាស្នេហាកាន់តែមានតម្លៃ វ័ន្ទព្រមហើយវិសេស! ព្រមទទួលយកបេះដូងដ៏ស្មោះរបស់អ្នក។ វ័ន្ទនឹងរក្សាបេះដូងព្រាត់ស្នេហ៍មួយនេះឱ្យស្មើនឹងជីវិតរបស់ខ្ញុំ! វ័ន្ទសូមសន្យាថាវ័ន្ទស្មោះពិតតែវិសេសមួយ។

វិសេស! ពេលនេះវ័ន្ទវិលវល់អស់ហើយ វ័ន្ទមិនចង់ទៅណាទេ វ័ន្ទចង់នៅក្បែរវិសេស ជាតិនេះបើគ្មានវិសេសនៅក្បែរវ័ន្ទមិនអាចមានក្ដីសុខបានឡើយ។ វ័ន្ទខ្លាចណាស់! តើគួរតែធ្វើយ៉ាងណា? វ័ន្ទមិនចង់បាត់បង់អ្នកទេវិសេស! វ័ន្ទបារម្ភខ្លាចស្នេហ៍របស់យើងរសាត់អណ្ដែតតាមពេលវេលា។ ពេលនេះវ័ន្ទដូចមនុស្សឆ្កួតអ៊ីចឹង វ័ន្ទខ្លាចអ្វីគ្រប់បែបយ៉ាង វ័ន្ទខ្លាចទ្រនិចនាឡិកា ហេតុអីក៏ដើរលឿនម្ល៉េះ? វិសេស! មួយអាទិត្យទៀតវ័ន្ទលាអ្នកហើយ។

ថ្ងៃចន្ទសប្តាហ៍ក្រោយនេះ វិសេសនឹងបានជួបរ័ត្នម្តងទៀត តែមិនដឹងថាការជួបគ្នានោះជាលើកចុងក្រោយ ឬយ៉ាងណានោះទេ! បើរ័ត្នលែងត្រឡប់វិញ តើវិសេសនៅចាំរ័ត្នដដែលឬយ៉ាងណា? វិសេសនៅស្រលាញ់រ័ត្នទៀតទេ? ប្រាប់មកវិសេស! ប្រាប់ការពិតឱ្យរ័ត្នបានដឹងផង ទោះជាចម្លើយអវិជ្ជមានក៏រ័ត្នមិនខឹងអ្នកដែរ ព្រោះរ័ត្នយល់ពីមូលហេតុទាំងនេះច្បាស់ណាស់។

យើងជួបគ្នាចុងក្រោយថ្ងៃចន្ទ ហើយប្រហែលជាពេលលារហូតក៏មិនដឹង...

ណារ័ត្ន

នៅតែស្រលាញ់អ្នក

*១៥-១០-២០០៣*

# អូនរ័ត្នបណ្ដូលចិត្តបង

រ័ត្ន! អូនពិតជាទៅហើយមែនទេ? អូនពិតជាទៅចោលបងហើយមែនទេ? បងមិននឹកស្មានសោះថាវានឹងឆាប់ដល់ម្ល៉ឹង យើងទាំងពីរនាក់កំពុងយល់ចិត្តគ្នា កំពុងតែចាប់ដៃគ្នាចងក្រងស្នេហាដ៏មានន័យ មានតម្លៃបំផុតក្នុងជីវិតតាមរយៈវាចាអក្ខរាដ៏ផ្អែមល្ហែមមានន័យ តែក៏គ្រាន់តែជារយៈពេលមួយដ៏សែនខ្លីសម្រាប់ស្នេហ៍យើង។

ពេលនេះវាក៏បានរំលងផុតហើយដែរ នៅសល់តែអក្ខរាមួយនេះដែលកំពុងសរសេរឱ្យអូន។ អក្ខរានេះវាពោរពេញទៅដោយសេចក្ដីឈឺចាប់បង្កប់ក្នុងនោះ។ ទោះបងនិងអូនបានដឹងហើយថានឹងមានថ្ងៃនេះ តែយើងទាំងពីរក៏នៅតែជម្នះ ពេលនេះគេចមិនរួចឡើយ យើងត្រូវបែកគ្នាកាន់តែឆ្ងាយហើយ។

រ័ត្នអើយ! អូនកុំខូចចិត្តពេកអី! បងយល់ហើយថាចិត្តអូនយ៉ាងណា បងក៏ខូចចិត្តមិនតិចដែរ តែយើងទាំងពីរមិនត្រូវទន់ខ្សោយនោះទេ។

រ័ត្ន! អូនស្ដាប់បងណ៎ា! ទោះជាអូននៅខ្មែរ ឬកាលណាជាក្ដី ក៏មួយរយៈមកនេះយើងមិនធ្លាប់ជួបគ្នាដែរ ស្នេហាយើងមានត្រឹមតែជាមទឹកប៊ិករំលេចពាក្យពេជ្របេះដូងតែប៉ុណ្ណោះ ពួកយើងរស់នឹកគ្នារហូត។ ពេលនេះយើងគួរត្រេកអរ ព្រោះយើងនឹងបានជួបគ្នានៅថ្ងៃចន្ទនេះហើយ។ ក្រោយស្នេហ៍ចាប់កំណើតនេះជាឱកាសឱ្យពួកយើងបានជួបគ្នា បន្ទាប់ពីនោះទៅ បងនឹងនៅតែនឹកអូនដដែល។

ណ្ហើយ! អូនឈប់គិតទៅ ទុកបញ្ហារបស់យើងឱ្យពេលវេលាជាអ្នកដោះស្រាយទៅចុះ! អ្នកណាក៏គេដឹងដែរ! ពាក្យសន្យារបស់អូនជាសម្ដីមាស បានជាសម្រេចចិត្តទៅហើយ អូនកុំស្ដាយក្រោយអី! អូនចាកចេញទៅដើម្បីអនាគត។ បើអូនបានសន្យាជាមួយម៉ាក់ធំរបស់អូនទៅហើយ អូនត្រូវគោរពសន្យារបស់អូនជាមួយគាត់ណ៎ា មិនត្រូវឱ្យគាត់ខកបំណងទេ។ តែអូនក៏ត្រូវគោរពសន្យាជាមួយបងដែរ អូនសន្យាជាមួយបងដោយផ្ទាល់ថាអូនស្មោះតែបងមួយ កុំក្បត់សន្យាណ៎ា បងក៏សូមស្បថថា មួយជីវិតនេះ គូជីវិតរបស់បងគឺអូនតែម្នាក់គត់! បើបងក្បត់សម្បថនេះជីវិតដែលគ្មានអូន បងនឹងរស់ដោយភាពសោកសៅព្រោះនឹកអូនរហូតថ្ងៃស្លាប់។

នេះជាសម្បថរបស់បង អូនជឿចុះ!

រ័ត្ន! អូនមិនត្រូវខ្លាចអ្វីទាំងអស់ ត្រូវចាំថាឱ្យតែយើងមានចិត្តស្មោះនឹងគ្នា ទោះជាអូនទៅដល់ទីណាក៏ក្តីស្នេហាបងអាចផ្ញើទៅដល់អូនដែរ។

រ័ត្ន! បងស្រលាញ់អូនខ្លាំងណាស់ ថ្ងៃចន្ទនេះយើងនឹងជួបគ្នា។ ថ្ងៃចន្ទនេះជាថ្ងៃជួបដំបូងសម្រាប់ក្តីស្នេហ៍យើងហើយណ៎ា។ អូនកុំភ្លេចណា! បងរង់ចាំថ្ងៃនោះ ទោះជាថ្ងៃជួបគ្នាចុងក្រោយនៃយើងទាំងពីរក៏បងសុខចិត្តដែរ។

**ពីបង**

**ស្នេហ៍អូនរហូត!**



# ស្នេហ៍គ្មាននិស្ស័យ

# ស្នេហ៍គ្មាននិស្ស័យ

ព្រលានយន្តហោះពោធិ៍ចិនតុង ណារ័ត្នានិងក្រុមគ្រួសារកំពុងឈរលាគ្នាពោលពេញដោយភាពសោកសៅ លាយទ្បំក្តីសង្ឃឹម។ ព្រោះចាស់ទុំរបស់ណារ័ត្នាជឿជាក់ណាស់ថានាងនឹងមានអនាគតល្អនៅលើដីកាណាដា។

ម៉ាក់របស់ណារ័ត្នានៅឈរឱបកូនស្រីមិនលែង ស្របពេលដែលប៉ារបស់នាងឈរសម្លឹងដោយទឹកមុខស្មើធេងផ្តាំទៅកូនស្រី៖

- កូនស្រី! កូនទៅដល់កូនខំរៀនណ៎ា!

ប៉ារបស់នាងអង្អែលក្បាលកូន ដែលកំពុងនៅជ្រកក្រោមដើមទ្រូងម្តាយនៅឡើយ។ ទឹកភ្នែករលីងរលោង ទាញមុខកូនស្រីមកបើបផ្ចិតពោលបន្ថែមវាចាស្វាមី៖

- កូនសម្លាញ់ម៉ាក់! បើកូនមានការលំបាកអ្វី កូនត្រូវប្រាប់ប៉ាម៉ាក់ឮទេកូន?

ម្តាយមីងដែលហៅនាងទៅកំដរនៅបាត់ដំបងអស់មួយរយៈកាលអង្អែលស្មាក្មួយស្រី សម្លឹងមុខម៉ាក់របស់ណារ័ត្នាស្តីបន្ទិចកុំឱ្យគាត់បារម្ភពេក៖

- អ្នកបងកុំបារម្ភអី! បងស្រីធំរបស់ពួកយើងនឹងមើលថែកូនរ័ត្នបានល្អណាស់!

លោកពូរបស់នាងដែលទើបត្រឡប់មកពីបរទេសនោះញញឹមទាំងមុខស្ងួតដាក់ម៉ាក់របស់ណារ័ត្ន និងពោលបន្ទរពាក្យភរិយាដោយសម្លឹងទៅប៉ារបស់នាង៖

- មែនហើយ! កុំបារម្ភអីលោកបង អ្នកបង! កូនរ័ត្នជាគ្រាប់ពេជ្ររបស់ពួកយើង ទោះនាងទៅដល់ទីណាក៏មិនអាចចេញផុតពីរង្វង់នៃក្តីស្រលាញ់របស់ពួកយើងបានដែរ។

ខ្នងដៃជូតទឹកភ្នែក ណារ័ត្នដកខ្លួនចេញពីការឱបរបស់ម្តាយ នាងខំដកដង្ហើមធំចេញចូលដើម្បីបន្ធូរភាពតានតឹងបន្តិចមុនឆ្លើយតបទៅចាស់ទុំជាទីស្រលាញ់របស់នាង៖

-ម៉ាក់ប៉ាកុំបារម្ភអី! លោកពូ ម៉ាក់មីង កូនអរគុណណាស់ដែលតែងតែស្រលាញ់មើលថែកូនមួយរយៈពេលដែលកូននៅស្នាក់ផ្ទះលោកទាំងពីរ លោកយកចិត្តទុកដាក់ចំពោះកូនណាស់។

-ម៉ាក់មីងណារ័ត្ន៖ កូនសម្លាញ់! ពួកយើងបីគ្រួសារមានកូនតែម្នាក់គត់ បើមិនឱ្យពួកយើងរួមគ្នាស្រលាញ់កូន តើឱ្យស្រលាញ់មើលថែអ្នកណា?

-លោកពូណារ័ត្ន៖ កូនរ័ត្ន! កូនកុំភ្លើតភ្លើននឹងវប្បធម៌ប្រទេសគេណាកូន! ទៅដល់ទីណាក៏ដោយចុះ ត្រូវប្រកាន់ចរិតជានារីខ្មែរឱ្យខ្ជាប់ខ្ជួន កុំឱ្យអាប់ឱនដល់ជាតិសាសន៍ណាកូន!

-ណារ័ត្ន៖ ចាស៎ លោកពូ! កូនមិនភ្លើតភ្លើនទេ!

លោកប៉ារបស់ណារ័ត្នមិនដាច់ចិត្តពីកូនស្រីសម្លាញ់ទាញប្រាណនាងឱបផ្អឹបក្បាលនៅដើមទ្រូងដោយក្តីបារម្ភនិងអាឡោះអាល័យ។

-កូនសម្លាញ់ប៉ា! ឱ្យប៉ាឱបកូនបន្តិច! កូនស្រីតែមួយ! កូនចាំណា កូនទៅនេះគឺទៅរៀន ទៅបំពេញមុខគ្រួសារ! កុំធ្វើខុសប្រពៃណីឱ្យសោះ! កុំទន់ខ្សោយឱ្យសោះ! មិនថាមានរឿងអីកើតឡើង កូនត្រូវរៀនជួយខ្លួនឯងសិនមុនហៅរកជំនួយ កូនស្រីប៉ាត្រូវតែរឹងមាំ!

លោកពូរបស់នាងហាក់ពេញចិត្តនឹងពាក្យផ្តែផ្តាំនេះគាត់ងក់ក្បាល ពោលបន្ទរ៖

-កូនរ័ត្ន! កូនស្រី! អ្នកទាំងអស់គ្នាស្រលាញ់កូនណាស់ តែពួកយើងមិនចង់ឱ្យកូនទន់ខ្សោយ ទើបត្រូវតែបំបែកកូនចេញពីទ្រូង ត្រូវឱ្យកូនរៀនរស់នៅរឹងមាំដោយខ្លួន រៀនចេះ

គ្រប់គ្រងជីវិតដោយខ្លួនឯង។

ណារ័ត្នដកខ្លួនចេញពីដើមទ្រូងឪពុក ជូតទឹកភ្នែកជាថ្មី៖

-ចាស៎លោកពូ! លោកប៉ា! កូនដឹងហើយ កូនមិនទន់ជ្រាយទេ! កូនមិនធ្វើខុសប្រពៃណីទេ កូនជឿណាស់ថាអ្នកទាំងអស់គ្នាស្រលាញ់កូន ចង់ឱ្យកូនល្អ។

ម៉ាក់ណារ័ត្នទាញកូនស្រីសំណព្វពីទ្រូងស្វាមីមកឱបថើប ទឹកភ្នែកមិនបាត់ស្រក់៖

-ម៉ាក់ណារ័ត្ន៖ កូនម្តាយ! បើមានឈឺថ្កាត់ កូនកុំលាក់! កូនត្រូវប្រាប់ម៉ាក់ធំណាកូនណ៎ា!

ណារ័ត្នយំឱបទ្រូងម្តាយដូចកូនក្មេង៖

-ណារ័ត្ន៖ ម៉ាក់...ហឹក..ហឹក..

ការរៀបរាប់លារបស់គ្រួសារណារ័ត្នហាក់មិនចេះចប់ នាងស្ងាត់យំបន្តិច នាងដកខ្លួនពីការឱបរបស់ម្តាយ ផ្តើមកើតចិត្តមិនស្កប់ ហេតុអ្វីមនុស្សជាទីស្រលាញ់ពីរនាក់ទៀតមិនឃើញមក? នាងដល់ពេលនឹងចេញទៅឥឡូវហើយ តើគេបាត់ទៅណា? ដៃទាំងគូញីភ្នែកឱ្យបាត់ស្រវាំងទឹកភ្នែកខំរំពៃរកមើលវិសេសម្ចាស់បេះដូង នុច្ចកាក៏មិនឃើញ ឬពួកគេមិនមកទេ? សំណួរប្រដេញពេញខួរក្បាល តែមិនមាន

អ្នកណាអាចប្រាប់នាងបាន ទឹកភ្នែកផ្ដើមហូររលីងរលោងម្ដងទៀត សម្លឹងជុំទីទៅជិតឆ្ងាយ សង្ឃឹមបានឃើញមនុស្សនាងចង់លា ស្រាប់តែទៅឃើញនុច្ចនី ប្អូនស្រីរបស់នុច្ចកាមិត្តសម្លាញ់ជំនួសទៅវិញ នាងតូចនុច្ចនីឈរវេរ៉េវដូចកំពុងរកមើលអ្វី ណារ័ត្នស្ទុះរឹងទៅរក ចោលមនុស្សចាស់ប្អូននាក់តាមមើលដំណើរចេញរបស់នាង។ ណារ័ត្នហាក់ខ្វល់ខ្វាយក្រៃលែង ម្ដងៗនាងស្រាប់តែមិនខ្វល់ពីអ្វី គ្រាន់តែចង់ដឹងថាវិសេស និងនុច្ចកាបាត់ទៅណា ហេតុអ្វីនុច្ចនីមានវត្តមាននៅទីនេះទៅវិញ? ទៅដល់ឈរពីមុខនុច្ចនី នាងចាប់ដៃប្អូនស្រីរបស់មិត្តសម្លាញ់សួរទាំងទោម្នេញ៖

-នី! អូនមកធ្វើអីហ្នឹង?

-អ៎បង! បងណារ័ត្ន! អូនមកទទួលមិត្តមកពីជប៉ុន ប៉ុន្ដែតែកុងឡានចតឱ្យអូនចុះខុសប្រេក នេះបងដូចជាកំពុងទៅណាមែនទេ?

- ចាស៎! បងទៅរៀននៅកាណាដាហើយអូន បងមិនច្បាស់ទេថាបងត្រឡប់មកវិញឬអត់។ បើតាមគម្រោង បងមិនមកវិញទេ បងអាចនឹងបង្កើតជីវិតថ្មីនៅទីនោះផងក៏មិនដឹង។

ណារ័ត្នអួលដើមកពេលនិយាយដល់អ្វីដែលមើលមិនឃើញ នុច្ចនីក្មេងតូចក្រោយដឹងមិត្តល្អរបស់បងស្រីមិនមានគម្រោងត្រឡប់មកវិញ ហាក់ស្ដាយស្រណោះមិនចង់បាត់បង់នាងតូចតាំងឈរយំអណ្ដឹតអណ្ដក ព្រមសំនួនវាចា៖

- អំបង...បងចាកចេញពីពួកយើងហើយ!

អាណិតប្អូនតូច ណារ័ត្នលើកដៃជូតទឹកភ្នែកលើថ្ពាល់ឱ្យនាង មិនឱ្យខាតពេលយូរ នាងផ្ដើមសួររឿងដែលធ្វើឱ្យទោម្នេញមិនទាន់បាត់៖

- កុំយំអីអូន អូនដឹងនុច្ចកានៅឯណាទេ?

នុច្ចនីនៅតែយំអណ្ដឹតអណ្ដកបែកក្មេង ខំឆ្លើយទៅណារ័ត្ន ទាំងសំឡេងយំត្រសិត៖

-ខ្ញុំអត់ដឹងទេបង! តែខ្ញុំឃើញថ្ងៃនេះគាត់ស្លៀកពាក់ស្អាតបាតចេញទៅជាមួយបងវិសេសទាំងព្រលឹម ខ្ញុំមិនបានសួរគាត់ថាទៅណាទេ។

-ទៅជាមួយវិសេស? (ណារ័ត្នសួរទាំងរន្ធាន់)

-ចាសបង! ថ្មីៗនេះឃើញគាត់ទៅណាមកណាជាមួយបងវិសេសតែរហូតហ្នឹង ពិសេសពីរបីថ្ងៃនេះ។

-អំ...! អរគុណហើយអូន បងដល់ពេលបងត្រូវឡើងយន្តហោះហើយ អូនរក្សាខ្លួនណ៎ា!